ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូង ខេត្តកំពង់ធំ

# តាងនាមប្រជារាស្ត្រខ្មែរ

-សាលក្រមព្រហ្មទណ្ឌលេខ : ០១ "ង"
ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០២១
-សំណុំរឿងព្រហ្មទណ្ឌលេខ : ៩៧៩
ចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០២០

-បានឃើញច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសអោយប្រើតាមព្រះរាជក្រម លេខ: នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១៤ ។

-ថ្ងៃបើកសវនាការជំនុំជម្រះ និង ថ្ងៃប្រកាសសាលក្រមជាសាធារណៈនៅថ្ងៃទី ០៥-មករា-២០២១ ។

**សមាសភាពចូលរួមសវនាការ មានដូចខាងក្រោម :**

លោក [redacted] ជាចៅក្រមជំនុំជម្រះ
លោក [redacted] ជាព្រះរាជអាជ្ញារង
កញ្ញា [redacted] ជាក្រឡាបញ្ជីសវនាការ
លោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

សាលាដំបូង ខេត្តកំពង់ធំ បានបើកសវនាការជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ : ៩៧៩ ចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០២០ ដែលជនជាប់ចោទមានសាវតាជាតិ ដូចខាងក្រោម:

-ឈ្មោះ [redacted] សំណាង ភេទប្រុស អាយុ៣៥ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរកាប់ឡោត។
-ទីកន្លែងកំណើតនៅភូ[redacted] ខេត្តកំពង់ចាម ។
-ទីលំនៅសព្វថ្ងៃភូមិ[redacted] ខេត្តសៀមរាប ។
-ប្រពន្ធឈ្មោះ [redacted]ចន្ទូ មានកូន០៤នាក់ ។
-ឪពុកឈ្មោះ [redacted] ណាន (រស់) ម្តាយឈ្មោះ [redacted] យ៉ន (រស់) ។

–ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន ។ ឃាត់ខ្លួនថ្ងៃទី ២១–ធ្នូ–២០២០ ។

**ជាប់ចោទពីបទ : លួច** ប្រព្រឹត្តនៅចំណុចផ្សារស្ទោង ឃុំកំពង់ចិនត្បូង ស្រុកស្ទោង ខេត្តកំពង់ធំ ប្រព្រឹត្តកាលពីថ្ងៃទី ១៨–ធ្នូ–២០២០ បទប្បញ្ញត្តិដែល មានចែង និង អោយផ្តន្ទាទោសតាមមាត្រា ៣៥៣ និង មាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

**ដើមបណ្តឹងរដ្ឋប្បវេណីមាន :**

**ក–[redacted] ឡៃស៊ា** ភេទស្រី អាយុ៧០ឆ្នាំ ទីលំនៅសព្វថ្ងៃភូមិកំពង់ក្តី ឃុំកំពង់ចិនត្បូង ស្រុកស្ទោង ខេត្តកំពង់ធំ ប្តីឈ្មោះ [redacted] វន មានកូន០៥នាក់ ឪពុកឈ្មោះ [redacted] លុញ (ស្លាប់) ម្តាយឈ្មោះ [redacted] លាង (ស្លាប់) ។

**ខ–[redacted] ញឹង** ភេទស្រី អាយុ៦៥ឆ្នាំ ទីលំនៅសព្វថ្ងៃភូមិទ្រា ឃុំទ្រា ស្រុកស្ទោង ខេត្តកំពង់ធំ ប្តីឈ្មោះ [redacted] ហ៊ួន (ស្លាប់) មានកូន០៦នាក់ ឪពុកឈ្មោះ [redacted] សុត្រ (ស្លាប់) ម្តាយឈ្មោះ [redacted] ហឿង (ស្លាប់) ។

**គ–[redacted] សុជឿន** ភេទស្រី អាយុ៥៨ឆ្នាំ ទីលំនៅសព្វថ្ងៃភូមិកំពង់ក្តី ឃុំកំពង់ចិនត្បូង ស្រុកស្ទោង ខេត្តកំពង់ធំ ប្តីឈ្មោះ [redacted] ឈន (ស្លាប់) មានកូន០២នាក់ ឪពុកឈ្មោះ [redacted] ប៊ុល (ស្លាប់) ម្តាយឈ្មោះ [redacted] ជ្រិច (ស្លាប់) ។

**ឃ–[redacted] ណាន** ភេទស្រី អាយុ៦២ឆ្នាំ ទីលំនៅសព្វថ្ងៃភូមិសាមគ្គោក ឃុំទ្រា ស្រុកស្ទោង ខេត្តកំពង់ធំ ប្តីឈ្មោះ [redacted] ណាំ មានកូន០៣នាក់ ឪពុកឈ្មោះ [redacted] ផុន (ស្លាប់) ម្តាយឈ្មោះ [redacted] សុំ (ស្លាប់) ។

**<u>បានឃើញ</u>**

–បានឃើញកំណត់ហេតុស្តីពីការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាមលេខ : ៥០ ចុះថ្ងៃទី ២៤–ធ្នូ–២០២០ របស់តំណាងអយ្យការ អមសាលាដំបូង ខេត្តកំពង់ធំ ។

–បានឃើញភស្តុតាង និងឯកសារពាក់ពន្ធ័ក្នុងសំណុំរឿង ។

**<u>ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ</u> :**

កាលពីថ្ងៃទី ១៨–ធ្នូ–២០២០ វេលាម៉ោង ៩,០០នាទីយប់ នៅចំណុចផ្សារស្ទោង ឃុំកំពង់ចិនត្បូង ស្រុកស្ទោង ខេត្តកំពង់ធំ មានបទល្មើស អំពើលួច ប្រព្រឹត្តឡើងដោយជនជាប់ចោទឈ្មោះ [redacted] សំណាង



Scanned with CamScanner

ភេទប្រុស អាយុ៣៥ឆ្នាំ បានធ្វើសកម្មភាពចូលទៅក្នុងផ្សារ ស្ទោងហើយបានលួចយកប្រហុកឆ្អឹង និង ប្រហុកសាច់ចំនួន០៤តួប សរុបមានចំនួន១០ប៉េត្រូ ប្រាកដមែន ។

រហូតដល់ថ្ងៃទី ២១-ធ្នូ-២០២០ ជនជាប់ចោទត្រូវបានសមត្ថកិច្ចស្រុកស្ទោងសហការណ៍ជាមួយកម្លាំងសមត្ថកិច្ចខេត្តសៀមរាបធ្វើការចាប់ខ្លួនជនជាប់ចោទនៅខេត្តសៀមរាបរួចហើយបញ្ជូនមកសាលាដំបូងខេត្តកំពង់ធំ តែម្តង ។

ចំណែកវត្ថុដែលចាប់យកមាន : ម៉ូតូម៉ាក HONDA DREAM ផលិតឆ្នាំ ២០២០ ពណ៌ខ្មៅ ផ្លាកលេខសៀមរាប 1AJ 1857 ចំនួន០១គ្រឿង ។

<u>**ចំលើយពិភាក្សាដេញដោលនាពេលសវនាការមាន**</u> :

**១-ជនជាប់ចោទឈ្មោះ [redacted] សំណាង បានឆ្លើយបញ្ជាក់ថា :** ខ្លួនពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ពិតប្រាកដមែន ដោយនៅថ្ងៃកើតហេតុខ្លួនឡើងមកពីខេត្តសៀមរាបមកដល់ស្រុកស្ទោងខេត្តកំពង់ធំនៅម៉ោងប្រហែល៩ព្រឹក ខ្លួនបានដើរចូលទៅផ្សារកំពង់ធំដើម្បីរកទិញប្រហុកយកទៅលក់បន្ត តែមិនត្រូវតម្លៃគ្នាលុះយប់ឡើងម៉ោងប្រហែល៩យប់ខ្លួនក៏បានចូលទៅក្នុងផ្សារ ស្ទោងបានចូលក្នុងតូបលក់ប្រហុកចំនួន៤តូបជាប់គ្នា ហើយបានលួចយកប្រហុកសរុបទាំងអស់មានចំនួន១០ធុងប៉េត្រូ ដាក់លើរ៉ឺម៉កម៉ូតូជិះទៅសៀមរាបវិញ ។

ព្រឹកឡើងខ្លួនបានដឹកប្រហុកនោះយកទៅលក់តាមផ្ទះ តាមផ្សារតូច ធំ ខ្លួនលក់ប្រហុកអស់ហើយបានប្រាក់ចំនួន ១.៩០០.០០០រៀល ។

ខ្លួនមិនដែលមកលួចប្រហុកនៅផ្សារ ស្ទោង ខេត្តកំពង់ធំនេះទេ គឺទើបតែលួចលើកទី១ប៉ុណ្ណោះ ។

នៅពេលដែលខ្លួនចូលលួចយកប្រហុកនោះគឺខ្លួនមិនឃើញមានសន្តិសុខយាមផ្សារទេ ហើយផ្សារក៏មិនមានចាក់សោរដែរ តែគេបើកភ្លើងភ្លឺពេញក្នុងផ្សារ ។

**២-ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីមាន :**

**ក-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ខ្សៀស៊ា បានឆ្លើយបញ្ជាក់ថា :** ចំពោះចោរដែលចូលលួចប្រហុកខ្លួនគឺខ្លួនមិនបានដឹងទេ ដោយវាលួចយកប្រហុកឆ្អឹងអស់ចំនួន៨ធុងប៉េត្រូ និង ប្រហុកសាច់ចំនួន៤ធុងប៉េត្រូ ។

ចំពោះប្រហុកឆ្អឹងខ្លួនលក់ចេញ១គីឡូក្រាម តម្លៃ ៨.០០០រៀល ឯប្រហុកសាច់ ខ្លួនលក់ចេញ១គីឡូក្រាម តម្លៃ ១៤.០០០រៀល ។

ខ្លួនសំណូមពរទាមទារសំណងថ្លៃបាត់បង់ប្រហុកចំនួន ១.០០០.០០០រៀល ។

**ខ–ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ញឹង បានឆ្លើយបញ្ជាក់ថា :** ចំពោះចោរដែលចូលលួចប្រហុកខ្លួនគឺខ្លួនមិនបានដឹងទេ ដោយវាលួចយកប្រហុកឆ្អឹងអស់ចំនួន២ធុងប៉េត្រូ ក្រៅពីនោះមិនមានបាត់បង់អ្វីទៀតទេ ។

ខ្លួនមិនទាមទារសំណងអ្វីទេ សុំឱ្យតុលាការសម្រេចតាមច្បាប់ ។

**គ–ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុជឿន បានឆ្លើយបញ្ជាក់ថា :** ចំពោះចោរដែលចូលលួចប្រហុកខ្លួនគឺខ្លួនមិនបានដឹងទេ ដោយវាលួចយកប្រហុកឆ្អឹងអស់ចំនួន០១បេ មានទម្ងន់១០០គីឡូក្រាម ក្រៅពីនោះខ្លួនមិនមានបាត់បង់អ្វីទៀតទេ ។

ខ្លួនសំណូមពរទាមទារសំណងថ្លៃបាត់បង់ប្រហុកចំនួន ៥០០.០០០រៀល ។

**ឃ–ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ណាត បានឆ្លើយបញ្ជាក់ថា :** ចំពោះចោរដែលចូលលួចប្រហុកខ្លួនគឺខ្លួនមិនបានដឹងទេ ដោយវាលួចយកប្រហុកឆ្អឹងអស់ចំនួន១ធុងប៉េត្រូ មានទម្ងន់ប្រហែល ២៨គីឡូក្រាម ។

ខ្លួនសំណូមពរទាមទារសំណងថ្លៃបាត់បង់ប្រហុកចំនួន ២៥០.០០០រៀល ។

**សេចក្តីកត់សម្គាល់ខ្លីៗ និង សំណូមពរចុងក្រោយរបស់ជនជាប់ចោទ**

សំណូមពរ សុំអោយតុលាការបន្ធូបន្ថយទោសដល់ខ្លួនផង ដើម្បីខ្លួនបានចេញទៅវិញទៅរកស៊ីចិញ្ចឹមកូន ពីព្រោះខ្លួនមានកូនតូចៗចំនួន០៤នាក់ ដោយមិនមានអ្នករកស៊ីចិញ្ចឹមនោះទេ ។

ខ្លួនដឹងពីកំហុសប្រព្រឹត្តរបស់ខ្លួនហើយ នៅពេលដែលខ្លួនបានចេញពីពន្ធនាគារវិញខ្លួនមិនប្រព្រឹត្តអំពើខុសច្បាប់ទៀតទេ ខ្លួននឹងខំធ្វើការរកស៊ីអំពើដែលមិនផ្ទុយច្បាប់ទៀតឡើយ ។

**តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា :**

ក្រោយបានបញ្ចប់ការសួរដេញដោលនាពេលសវនាការ ក្រោយបានស្តាប់អំណានឯកផ្សេងៗ និងក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី តំណាងអយ្យការយល់ឃើញថា ពិតជាបានអង្គហេតុអំពើលួច ប្រព្រឹត្តឡើងដោយជនជាប់ចោទឈ្មោះ [redacted]សំណាង ភេទប្រុស បានចូលលួចយកប្រហុកក្នុងផ្សារស្មោងចំនួន១០ប៉េត្រូ ពិតប្រាកដមែន ។

ជនជាប់ចោទបានឆ្លើយសារភាពនាពេលសវនាការនេះថា ខ្លួនពិតជាបានចូលទៅលួចយកប្រហុកក្នុងផ្សារស្មោងចំនួន១០ប៉េត្រូ រួចដឹករ៉ឺម៉កយកទៅលក់នៅខេត្តសៀមរាប ពិតមែន ចម្លើយសារភាពនេះស៊ីសង្វាក់ទៅនឹងចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។

ដូច្នេះតំណាងអយ្យការស្នើសុំឱ្យតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

**មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា :**

ឆ្លងតាមការសួរដេញដោលនាពេលសវនាការនេះ ឃើញថាកូនក្តីរបស់បានឆ្លើយសារភាពនូវអំពើប្រព្រឹត្តរបស់ខ្លួនដោយឥតមានការលាក់លៀមឡើយ ហើយការព្រឹត្តរបស់កូនក្តីគឺមកពីមូលហេតុកូនក្តីរបស់ខ្លួនមានជីវភាពទីទាល់ក្រពេក ម្យ៉ាងទៀតកូនក្តីរបស់ខ្លួនមានកូនតូចរហូតដល់០៤នាក់ក្នុងបន្ទុកដែលត្រូវរកស៊ីចិញ្ចឹម ។

អំពើប្រព្រឹត្តរបស់កូនក្តីខ្លួនមិនបង្កឱ្យមានព្យុះសនកម្មធ្ងន់ធរនោះទេ ដូច្នេះខ្លួនស្នើសុំឱ្យតុលាការមេត្តាបន្ធូបន្ថយទោសដល់កូនក្តីខ្លួន ដោយផ្តល់ការព្យួរទោសដល់កូនក្តីរបស់ខ្លួនផង ដើម្បីឱ្យកូនក្តីរបស់ខ្លួនមានលទ្ធភាពចេញទៅរកស៊ីចិញ្ចឹមកូនៗវិញ ពីព្រោះគ្រួសាររបស់កូនក្តីខ្លួនពឹងផ្អែកតែលើកូនក្តីរបស់ខ្លួននេះតែម្នាក់ប៉ុណ្ណោះ ។

ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

ក្រោយពីស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

ក្រោយពីបានស្តាប់សេចក្តីកត់សម្គាល់ខ្លី និង សំណូមពរចុងក្រោយរបស់ជនជាប់ចោទ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

ក្រោយពីបានពិនិត្យភស្តុតាង និងឯកសារពាក់ពន្ធ័ក្នុងសំណុំរឿង

**<u>សាលាដំបូង ខេត្តកំពង់ធំ</u>**

**<u>យល់ឃើញថា</u>**

១-កាលពីថ្ងៃទី ១៨-ធ្នូ-២០២០ វេលាម៉ោង ៩,០០នាទីយប់ នៅចំណុចផ្សារស្ទោង ឃុំ កំពង់ចិនត្បូង ស្រុកស្ទោង ខេត្តកំពង់ធំ ពិតជាមានបទល្មើស អំពើលួច ប្រព្រឹត្តឡើងដោយ ជនជាប់ចោទឈ្មោះ និន សំណាង ភេទប្រុស អាយុ៣៥ឆ្នាំ បានធ្វើសកម្មភាពចូលទៅក្នុងផ្សារស្ទោងហើយបានលួចយកប្រហុកឆ្អឹង និង ប្រហុកសាច់ចំនួន០៤តួប សរុបមានចំនួន១០ប៉េត្រូ ប្រាកដមែន ។

២-ចម្លើយនាពេលេសវនាការមាន :

ក-ជនជាប់ចោទឈ្មោះ [redacted] សំណាង បានឆ្លើយបញ្ជាក់ថា : ខ្លួនពិតជាបានចូលទៅក្នុងផ្សារស្ទោងនិងបានលួចយកប្រហុកចំនួន១០ប៉េត្រូ ប្រាកដមែន ។

ខ-ដើមបណ្តឹងរដ្ឋប្បវេណីទាំង៤នាក់បានឆ្លើយប្រហាក់ប្រហែលគ្នាថា : ពួកខ្លួនពិតជាបានបានប្រហុកឆ្អឹង និង ប្រហុកសាច់ ពិតមែន ។



Scanned with CamScanner

៣-តាមចម្លើយសារភាពរបស់ជនជាប់ចោទ ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និង របាយការណ៍នានារបស់មន្ត្រីនគរបាលយុត្តិធម៌ឃើញថាមានលក្ខណៈស៊ីសង្វាក់គ្នាដែលបង្ហាញឱ្យឃើញច្បាស់ថា គឺថ្ងៃទី ១៨-ធ្នូ-២០២០ ជនជាប់ចោទឈ្មោះ [redacted] សំណាង ពិតជាបានចូលទៅលួចប្រហុកឆ្អឹង និង ប្រហុកសាច់ក្នុងផ្សារស្ទោង ពិតមែន ។

ដូច្នេះអាចឱ្យតុលាការសន្និដ្ឋានបានពីអំពើរបស់ជនជាប់ចោទដែលប្រព្រឹត្តឡើងមក គឺជនជាប់ចោទពិតជាបានប្រព្រឹត្តនូវបទល្មើស អំពើលួច ដែលល្មើសនឹងមាត្រា ៣៥៣ និង មាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ។

៤-ជនជាប់ចោទបានស្នើសុំអោយតុលាការបន្ធូបន្ថយទោសដល់ខ្លួនផល ការស្នើសុំនេះ តុលាការនឹងទទួលមកពិចារណា និងគប្បីផ្តល់ការព្យួរទោសមួយផ្នែកដល់ជនជាប់ចោទ ដោយហេតុថា អំពើរបស់ជនជាប់ចោទប្រព្រឹត្តឡើងមានព្យុះសនកម្មតូចតាច ហើយដើមបណ្តឹងរដ្ឋប្បវេណីខ្លះបានទាមទារសំណង និង ដើមបណ្តឹងរដ្ឋប្បវេណីខ្លះមិនទាមទារសំណងនោះទេ ដូច្នេះគប្បីតុលាការផ្តន្ទាទោសជនជាប់ចោទ ដោយផ្តល់ការព្យួរទោសមួយផ្នែកនៃទោសពន្ធនាគារ ។

យោងតាមមាត្រា ១០៨ នៃក្រម ព្រហ្មទណ្ឌ ចែងថា តុលាការអាចសម្រេចថា ការព្យួរទោសធម្មតានេះ អាចនឹងអនុវត្តទៅលើមួយផ្នែកនៃទោសពន្ធនាគារ ដែលតុលាការជាអ្នកកំណត់ថិរវេលា។

៥-ដើមបណ្តឹងរដ្ឋប្បវេណីមានប្តឹងទាមសំណងថ្លៃបាត់បង់ប្រហុកមាន :

ក-ឈ្មោះ [redacted] ឡៃស៊ា ទាមទារសំណងចំនួន ១.000.000រៀល (មួយលានរៀល) ។

ខ-ឈ្មោះ [redacted] សុជឿន ទាមទារសំណងចំនួន ៥00.000រៀល (ប្រាំសែនរៀល) ។

គ-ឈ្មោះ [redacted] ណាន ទាមទារសំណងចំនួន ២៥0.000រៀល (ម្ភៃប្រាំម៉ឺនរៀល) ។

ការប្តឹងទាមទារសំណងនេះ តុលាការនឹងទទួលមកពិចារណាតាមការជាក់ស្តែង ដោយតាមមាត្រា ៣៥៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៦-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំ ឱ្យតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ។ ការប្តឹងសុំនេះ តុលាការនឹងទទួលមកពិចារណារតាមការស្នើសុំ។

៧-វត្ថុដែលចាប់យកមាន : ម៉ូតូម៉ាក HONDA DREAM ផលិតឆ្នាំ ២០២០ ពណ៌ខ្មៅ ផ្លាកលេខសៀមរាប 1AJ 1857 ចំនួន០១គ្រឿង ។ គប្បីតុលាការសម្រេចប្រគល់ឱ្យទៅម្ចាស់ដើមវិញ ដោយយោងតាមមាត្រា ៣៥៤ នៃនីតិវិធីព្រហ្មទណ្ឌ ។

៨-មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] សំណាង ភេទប្រុស ដែលមានសាវតាជាតិខាងលើ ពីបទ : លួច ប្រព្រឹត្តនៅចំណុចផ្សារស្ទោង ឃុំកំពង់ចិនត្បូង ស្រុកស្ទោង ខេត្តកំពង់ធំ ប្រព្រឹត្តកាលពីថ្ងៃទី ១៨-ធ្នូ-២០២០ បទប្បញ្ញត្តិដែលមានចែង និង ឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និង មាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។



Scanned with CamScanner

## ហេតុដូច្នេះសាលាដំបូង ខេត្តកំពង់ធំ

## វិនិច្ឆ័យសេចក្តី

១–ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] **សំណាង ភេទប្រុស អាយុ៣៥ឆ្នាំ ដែលមានសាវតាជាតិខាងលើ** ដាក់ពន្ធនាគារកំណត់ចំនួន ០៦ខែ (ប្រាំមួយខែ) ទោសពន្ធនាគារនេះ ជនជាប់ចោទត្រូវទទួលអនុវត្តក្នុងពន្ធនាគារចំនួន ០១ខែ (មួយខែ) ដោយអនុវត្តទោសគិតពីថ្ងៃឃាត់ខ្លួនថ្ងៃទី ២១–ធ្នូ–២០២០ ទោសដែលនៅសល់ត្រូវព្យួរធម្មតា **ពីបទ : លួច** ប្រព្រឹត្តនៅចំណុចផ្សារស្ទោង ឃុំកំពង់ចិនត្បូង ស្រុកស្ទោង ខេត្តកំពង់ធំ ប្រព្រឹត្តកាលពីថ្ងៃទី ១៨–ធ្នូ–២០២០ បទប្បញ្ញត្តិដែលមានចែង និង ឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ , ៣៥៦ និង មាត្រា ១០៨ នៃក្រមព្រហ្មទណ្ឌ។

២–បង្គាប់ឱ្យជនជាប់ចោទឈ្មោះ [redacted] **សំណាង** បង់ប្រាក់សំណងឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីដូចខាងក្រោម :

**ក**–ឈ្មោះ [redacted] **ឡៃស៊ា** ចំនួន ៨00.000រៀល (ប៉ែត្រសិបម៉ឺនសែនរៀល) សំណូមពរទាមទារលើសពីនេះ ត្រូវបដិសេធចោល ។

**ខ**–ឈ្មោះ [redacted] **សុជឿន** ចំនួន ៤00.000រៀល (សែសិបម៉ឺនរៀល) សំណូមពរ ទាមទារលើសពីនេះ ត្រូវបដិសេធចោល ។

**គ**–ឈ្មោះ [redacted]**ណាន** ចំនួន ២៥0.000រៀល (ម្ភៃប្រាំម៉ឺនរៀល) ។

៣–ប្រគល់វត្ថុដែលចាប់ឱ្យទៅម្ចាស់ដើមវិញមាន : ម៉ូតូម៉ាក HONDA DREAM ផលិតឆ្នាំ ២០២០ ពណ៌ខ្មៅ ផ្លាកលេខ សៀមរាប 1AJ 1857 ចំនួន០១គ្រឿង ។

សាលក្រមនេះជំនុំជម្រះ និង ប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ និង ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី ប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

**ក្រឡាបញ្ជី**

**ហត្ថលេខា និង ត្រា** [redacted]

**ចៅក្រមជំនុំជម្រះ**

**ហត្ថលេខា និង ត្រា** [redacted]

---

**បានថតចម្លងចេញត្រឹមត្រូវតាមសាលក្រមដើម**

**ថ្ងៃពុធ ៨រោច ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស ២៥៦៤**

**កំពង់ធំ . ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០២១**

**បានឃើញ**

**ចៅក្រមជំនុំជម្រះ**

[redacted]

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner